**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ព្រឹត្តិបត្រស្ថិតិ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រចាំត្រីមាសទី៣ ឆ្នាំ២០២៣

**អគ្គនាយកដ្ឋានគោលនយោបាយ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ខែវិច្ឆិកា ឆ្នាំ២០២៣

# មាតិកា

សេចក្តីអធិប្បាយសង្ខេប ....................................................... ១

តារាងស្ថិតិសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ....................................................... ៤

១. សូចនាករសេដ្ឋកិច្ចសំខាន់ៗ ....................................................... ៤

២. សូចនាករតាមវិស័យ ....................................................... ៦

២.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ....................................................... ៦

២.២. អត្រាប្តូរប្រាក់ ....................................................... ៧

២.៣. ស្ថានភាពហិរញ្ញវត្ថុសាធារណៈ ....................................................... ៨

២.៤. ស្ថានភាពរូបិយវត្ថុ និងឥណទាន ....................................................... ១០

២.៥. ស្ថានភាពពាណិជ្ជកម្ម ....................................................... ១៤

២.៦. ស្ថានភាពវិនិយោគឯកជន ....................................................... ១៨

២.៧. ស្ថានភាពទេសចរណ៍ ....................................................... ១៩

២.៨. ស្ថានភាពសំណង់ ....................................................... ២១

៣. ថ្លៃទំនិញសំខាន់ៗ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ ....................................................... ២២

# សេចក្តីអធិប្បាយសង្ខេប

ស្ថានភាពសេដ្ឋកិច្ចសកល ត្រូវបានវាយតម្លៃដោយអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) កាលពីខែតុលា ឆ្នាំ២០២៣ បង្ហាញថា កំណើននឹងសម្រេចបាន ៣% នៅឆ្នាំ២០២៣ និង សម្រេចបាន ២,៩% នៅឆ្នាំ២០២៤។ ជាមួយគ្នានេះ ស្ថានភាពសេដ្ឋកិច្ចសកល ក៏នៅតែប្រឈមនឹងភាពមិនប្រាកដប្រជាមួយចំនួន ដូចជា ការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ, អត្រាអតិផរណាគោលនៅតែស្ថិតក្នុងកម្រិតខ្ពស់, លក្ខខណ្ឌមិនស្វរអំណោយផលក្នុងវិស័យហិរញ្ញវត្ថុ, ការផ្ទុះសង្គ្រាមនៅតំបន់មជ្ឈិមបូព៌ា, សង្គ្រាមនៅអ៊ុយក្រែនបន្តអូសបន្លាយ និងភាពតានតឹងភូមិសាស្ត្រនយោបាយក្នុងតំបន់និងសកល។

ទន្ទឹមនេះ សេដ្ឋកិច្ចកម្ពុជា ត្រូវបានប៉ាន់ស្មានថានឹងសម្រេចបានក្នុងអត្រា ៥,៦%[1] នៅឆ្នាំ២០២៣ ខ្ពស់ជាង ឆ្នាំ២០២២។ អត្រាកំណើននេះ គាំទ្រដោយការរក្សាបានកំណើនល្អ នៃកម្មន្តសាលមិនមែនកាត់ដេរ ដែលបម្រើឱ្យការនាំចេញ និងការប្រើប្រាស់ក្នុងស្រុក, ការកើនឡើងនូវគម្រោងវិនិយោគឯកជន, ការកើនឡើងនូវតម្លៃគម្រោងសាងសង់សំណង់ និងការងើបឡើងគួរឱ្យកត់សម្គាល់នៃវិស័យទេសចរណ៍។ ជាការសង្កេត នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៣ ដោយឈរលើស្ថានភាពសូចនាករសំខាន់ៗ បានបង្ហាញថាស្ថានភាពសេដ្ឋកិច្ចជារួមល្អប្រសើរ តាមរយៈកំណើនចំនួនភ្ញៀវទេសចរអន្តរជាតិប្រមាណ ៧៧,៥%, កំណើនទុននៃគម្រោងវិនិយោគឯកជនប្រមាណ ២៣១,៧%, កំណើនតម្លៃនៃគម្រោងសាងសង់សំណង់ប្រមាណ ១៩២,៣%, កំណើនទឹកប្រាក់នៃការនាំចេញទំនិញ(ដកមាស) ប្រមាណ ៧,២% និងស្ថិរភាពនៃអត្រាប្តូរប្រាក់ ព្រមទាំងអតិផរណាស្ថិតក្នុងកម្រិតទាប។

**អតិផរណា និង អត្រាប្តូរប្រាក់**[2]

អតិផរណាមធ្យមប្រចាំត្រីមាសទី៣ ឆ្នាំ២០២៣ មានអត្រា ១,៤% ធៀបនឹងត្រីមាសមុន និង មានអត្រា ៣% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២ ដោយសារការកើនឡើង នៃសន្ទស្សន៍ថ្លៃទំនិញសឹងគ្រប់មុខ ជាពិសេសសន្ទស្សន៍ថ្លៃម្ហូបអាហារ, សន្ទស្សន៍ថ្លៃភោជនីយដ្ឋាន, សន្ទស្សន៍ថ្លៃផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ននិងឥន្ទនៈដទៃទៀត។ ទន្ទឹមនេះ អត្រាប្តូរប្រាក់ជាមធ្យមក្នុងរង្វង់ ៤ ១៣២,៦ រៀល/ដុល្លារអាម៉េរិក បានកើនឡើង ០,៧% ធៀបនឹងត្រីមាសមុន និងបានកើនឡើង ០,៨% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២។

**ស្ថានភាពហិរញ្ញវត្ថុសាធារណៈ:**[3]

ក្នុងត្រីមាសទី៣ ឆ្នាំ២០២៣ ការប្រមូលចំណូល អនុវត្តបានសរុបចំនួន ៥ ៤១៤,៤ ប៊ីលានរៀល (ស្មើ ២០,៩% នៃច្បាប់ថវិកាប្រចាំឆ្នាំ) បានធ្លាក់ចុះ ១៥,៧% ធៀបនឹងត្រីមាសមុន និង បានធ្លាក់ចុះ ៦,៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២ ក្នុងនោះ ចំណូលចរន្តសរុប ៥ ៤០៥,១ ប៊ីលានរៀល បានធ្លាក់ចុះ ១៥,៦% ធៀបនឹងត្រីមាសមុន និង បានធ្លាក់ចុះ ៧,៧% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ការធ្លាក់ចុះនេះ គឺដោយសារការធ្លាក់ចុះនៃការប្រមូលចំណូលសារពើពន្ធ ជាពិសេសពន្ធលើអាករលើតម្លៃបន្ថែម, អាករពិសេស និងចំណូលពន្ធលើការនាំចូល។ រីឯ ចំណាយសរុបអនុវត្តបានចំនួន ៧ ១៥៤,៧ ប៊ីលានរៀល (ស្មើនឹង ២០,៦% នៃច្បាប់ថវិកាប្រចាំឆ្នាំ) បានធ្លាក់ចុះ ៣,១% ធៀបនឹងត្រីមាសមុន ប៉ុន្តែបានកើនឡើង ១៣,៧% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២ ខណៈដែល

---

[1] ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៤

[2] ទិន្នន័យពីវិទ្យាស្ថានជាតិស្ថិតិ/ក្រសួងផែនការ និងធនាគារជាតិ នៃកម្ពុជា

[3] ទិន្នន័យពីអគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ចំណាយចរន្តសរុបអនុវត្តបានចំនួន ៤ ៦៦១,៨ ប៊ីលានរៀល បានកើនឡើង ២,២% ធៀបនឹងត្រីមាសមុន និងបានកើនឡើង ១១,៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២។ ការកើនឡើងនេះគឺដោយសារការបន្តកើនឡើងលើការចំណាយចន្តរ ដូចជាការចំណាយការពារនិងសន្តិសុខជាតិ, ការចំណាយរដ្ឋបាលស៊ីវិល និងការចំណាយការប្រាក់។ ជាលទ្ធផលនៃការអនុវត្តថវិកាចរន្ត មានអតិរេកចំនួន ៧៤៣,៤ ប៊ីលានរៀល។

**ស្ថានភាពរូបិយវត្ថុ និងឥណទាន**[4]

គិតត្រឹមត្រីមាសទី៣ ឆ្នាំ២០២៣ រូបិយវត្ថុទូទៅ (M2) មានសរុបចំនួន ១៨៧,២ ទ្រីលានរៀល បានកើនឡើង ២,៦% ធៀបនឹងត្រីមាសមុន និង បានកើនឡើង ១០,៥% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២ ខណៈដែលទុនបម្រុងរូបិយបណ្ណបរទេសដុល មានសរុបចំនួន ១៨,១ ប៊ីលានដុល្លារអាមេរិក បានធ្លាក់ចុះ ១,៧% ធៀបនឹងត្រីមាសមុន និងបានធ្លាក់ចុះ ២,៣% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២។ ទន្ទឹមនេះ ឥណទានដែលផ្តល់ដោយធនាគារពាណិជ្ជ មានសរុបចំនួន ២២០ ទ្រីលានរៀល បានកើនឡើង ១០,៨% ធៀបនឹងត្រីមាសមុន និង បានកើនឡើង ១៦,៥% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២ ដែលភាគច្រើនបានផ្តល់ទៅគ្រឹះស្ថានមិនបម្រើសេវាហិរញ្ញវត្ថុ ដូចជា ការលក់ដុំ-លក់រាយ, ការជួញដូរអចលនទ្រព្យ, ការសាងសង់ និងកសិកម្ម។

**ពាណិជ្ជកម្មក្រៅប្រទេស**[5]

ក្នុងត្រីមាសទី៣ ឆ្នាំ២០២៣ បើមិនរាប់បញ្ចូលមាស, ការនាំចេញ មានទឹកប្រាក់សរុបចំនួន ៦ ០២២,២ លានដុល្លារអាមេរិក ធៀបនឹងត្រីមាសមុន និងត្រីមាសដូចគ្នាឆ្នាំ២០២២ បានកើនឡើង ៧,២% ដូចគ្នា ដោយសារការកើនឡើង នៃការនាំចេញបន្ទះសូឡានិងឌីយ៉ូត, គ្រឿងសង្ហារិម, ស្បែកសត្វមានរោមសម្រាប់កែច្នៃជាសម្លៀកបំពាក់, គ្រឿងអេឡិចត្រូនិក, គ្រឿងបន្លាស់រថយន្ត, និងផលិតផលកសិកម្មមួយចំនួន ដូចជាដំឡូងមី, កៅស៊ូ, អង្ករ, ស្វាយចន្ទី និងស្ករស ជាដើម។ រីឯ ការនាំចូល មានទឹកប្រាក់សរុបចំនួន ៥ ៩៨៧,៥ លានដុល្លារអាមេរិក បានធ្លាក់ចុះ ៦% ធៀបនឹងត្រីមាសមុន និងបានធ្លាក់ចុះ ៥,៧% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២ ដោយសារការធ្លាក់ចុះ នៃការនាំចូលក្រណាត់, ប្រេងឥន្ធនៈ និងយានយន្ត ជាដើម។

**ទេសចរណ៍**[6]

ក្នុងត្រីមាសទី៣ ឆ្នាំ២០២៣ ភ្ញៀវទេសចរអន្តរជាតិ មានសរុបចំនួន ១,៣ លាននាក់ បានកើនឡើង ៤,៥% ធៀបនឹងត្រីមាសមុន និងបានកើនឡើង ៧៧,៥% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២។ កំណើននេះ គឺដោយសារភ្ញៀវទេសចរអន្តរជាតិ ដែលបានបង្វែរទិសពីតំបន់មជ្ឈិមបូព៌ា និងអឺរ៉ុប ដើម្បីបញ្ចៀសពីផលប៉ះពាល់ នៃសង្គ្រាមនៅអ៊ុយក្រែន និងនៅតំបន់មជ្ឈិមបូព៌ា ព្រមទាំងការដាក់ចេញវិធានការបន្ថែមរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់បន្តការគ្រប់គ្រងផលប៉ះពាល់ និងបន្តគាំទ្រដល់វិស័យទេសចរណ៍។

---

[4] ទិន្នន័យពីធនាគារជាតិ នៃកម្ពុជា

[5] ទិន្នន័យពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

[6] ទិន្នន័យពីក្រសួងទេសចរណ៍

**វិនិយោគឯកជន** [7]

ក្នុងត្រីមាសទី៣ ឆ្នាំ២០២៣ គម្រោងវិនិយោគដែលបានអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសរុបចំនួន ៧៨ គម្រោង បានកើនឡើង ៥,៤% ធៀបនឹងត្រីមាសមុន និងបានកើនឡើង ៥០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២។ រីឯ ទំហំទុនវិនិយោគ មានសរុបចំនួន ១ ១៩៩,២ លានដុល្លារអាម៉េរិក បានកើនឡើង ៥៧,៧% ធៀបនឹងត្រីមាសមុន និងបានកើនឡើង ២៣១,៧% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២។ ការកើននេះ គឺដោយមានការកើនឡើងគម្រោងវិនិយោគលើវិស័យឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន ដូចជាការវិនិយោគលើគម្រោងផ្លូវល្បឿនលឿនភ្នំពេញ-បាវិត, គម្រោងអភិវឌ្ឍន៍អនុស្ថានីយ៍និងខ្សែបញ្ជូនថាមពលអគ្គិសនី, ការកែច្នៃចំណីអាហារ, ការកែច្នៃដំឡូងមី, ការកែច្នៃកៅស៊ូ, រោងចក្រផលិតដែក និងការពង្រីកផលិតកម្ម ជាដើម។

**សំណង់** [8]

ក្នុងត្រីមាសទី៣ ឆ្នាំ២០២៣ គម្រោងសំណង់ទូទាំងប្រទេស មានសរុបចំនួន ៧៤៩ គម្រោង បានធ្លាក់ចុះ ៩,៣% ធៀបនឹងត្រីមាសមុន និងបានធ្លាក់ចុះ ៣៦,៣% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២ ប៉ុន្តែតម្លៃគម្រោងសាងសង់មានសរុបចំនួន ២ ២០០,២ លានដុល្លារអាម៉េរិក បានកើនឡើង ៤៩,២% ធៀបនឹងត្រីមាសមុន និងបានកើនឡើង ១៩២,៣% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២។ ការកើនឡើងនៃតម្លៃគម្រោងនេះ គឺភាគច្រើនជាប្រភេទសំណង់លំនៅឋាន, សំណង់ពាណិជ្ជកម្ម សំណង់ឧស្សាហកម្ម និងសំណង់ទេសចរណ៍។

**ថ្លៃទំនិញសំខាន់ៗ** [9] **លើទីផ្សារអន្តរជាតិ**

ក្នុងត្រីមាសទី៣ ឆ្នាំ២០២៣ ថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិគិតជាមធ្យម ដូចជា ថ្លៃប្រេងឆៅ ៨៥,៣ ដុល្លារអាម៉េរិក/ធុង បានកើនឡើង ១១,៣%, អង្ករ ៦០០,៧ ដុល្លារអាម៉េរិក/តោន បានកើនឡើង ១៨,២% និងសន្ទស្សន៍ថ្លៃថាមពល ១០៩,១ បានកើនឡើង ៨,៦% ខណៈដែលមាស ២ ១១៥,៩ ដុល្លារអាម៉េរិក/អោន បានធ្លាក់ចុះ ២,៥% និងកៅស៊ូ (TSR20) ១ ៣៣៦,៦ ដុល្លារអាម៉េរិក/តោន បានធ្លាក់ចុះ ០,៤%, សន្ទស្សន៍ថ្លៃមិនមែនថាមពល ១១០,២ បានធ្លាក់ចុះ ២% និងសន្ទស្សន៍ថ្លៃលោហធាតុមានតម្លៃ ១៤៦,៦ បានធ្លាក់ចុះ ២,៦% ធៀបនឹងត្រីមាសមុន។ បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២, ថ្លៃអង្ករ បានកើន ៣៩,៩%, មាស បានកើនឡើង ១១,៧%, សន្ទស្សន៍ថ្លៃលោហធាតុមានតម្លៃ បានកើនឡើង ១៣,២% ប៉ុន្តែថ្លៃប្រេងឆៅ បានធ្លាក់ចុះ ១១,៥% និងកៅស៊ូ (TSR20) បានធ្លាក់ចុះ ៧,៦%, សន្ទស្សន៍ថ្លៃថាមពល បានធ្លាក់ចុះ ៣៤,២% និងសន្ទស្សន៍ថ្លៃមិនមែនថាមពល បានធ្លាក់ចុះ ៥,១%។

---

[7] ទិន្នន័យពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)

[8] ទិន្នន័យពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

[9] ទិន្នន័យពីគេហទំព័រធនាគារពិភពលោក និងសម្គាល់÷សន្ទស្សន៍ថ្លៃថាមពល (ធ្យូងថ្ម, ប្រេងឆៅ និងឧស្ម័ន), មិនមែនថាមពល (លោហធាតុ, កសិកម្ម និងជីគីមី) និងលោហធាតុមានតម្លៃ (មាស, ប្រាក់ និងប្លាទីន)

# តារាងស្ថិតិសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ១. សូចនាករសេដ្ឋកិច្ចសំខាន់ៗ

*តារាង ១÷ ទិន្នន័យសេដ្ឋកិច្ចសំខាន់ៗ*

| បរិយាយ | ឯកតា | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|---|
| | | ត្រីមាសទី៣ | ត្រីមាសមុន | ត្រីមាសទី៣ឆ្នាំមុន | ៩ខែដើមឆ្នាំមុន |
| **សូចនាករម៉ូលដ្ឋាន (ជាមធ្យម)** | | | | | |
| សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ | | 204.19 | 1.4% | 3.0% | 1.8% |
| អត្រាប្តូរប្រាក់ | រៀល/ ដុល្លារអាមេរិក | 4,132.52 | 0.7% | 0.8% | 0.8% |
| **ហិរញ្ញវត្ថុសាធារណៈ** | | | | | |
| ចំណូលចរន្ត | ប៊ីលានរៀល | 5,405.13 | -15.6% | -6.6% | -0.8% |
| ចំណាយចរន្ត | ប៊ីលានរៀល | 4,661.76 | 2.2% | 11.6% | 13.2% |
| តុល្យភាពថវិកាចរន្ត | ប៊ីលានរៀល | 743.37 | -59.7% | -53.7% | -28.0% |
| **រូបិយវត្ថុ និងឥណទាន** | | | | | |
| រូបិយវត្ថុទូទៅ (M2) | ប៊ីលានរៀល | 187,237.55 | 2.6% | 10.5% | 9.2% |
| ឥណទាន* | ប៊ីលានរៀល | 241,277.70 | 1.1% | 6.5% | 10.2% |
| ឥណទេយ្យក្នុងស្រុក | ប៊ីលានរៀល | 212,828.17 | 1.9% | 7.7% | 11.3% |
| ទុនបម្រុងរូបិយបណ្ណបរទេសសុទ្ធ | លានដុល្លារអាមេរិក | 18,070.63 | -1.7% | 2.3% | -5.1% |
| **ពាណិជ្ជកម្មអន្តរជាតិ** | | | | | |
| ទំហំនាំចេញទំនិញ | លានដុល្លារអាមេរិក | 6,132.53 | 1.0% | 4.3% | 2.0% |
| ទំហំនាំចូលទំនិញ | លានដុល្លារអាមេរិក | 6,042.61 | -5.1% | -23.5% | -23.1% |
| តុល្យភាពពាណិជ្ជកម្ម | លានដុល្លារអាមេរិក | 89.91 | -130.3% | -104.5% | -89.6% |
| **វិនិយោគឯកជន** | | | | | |
| គម្រោងវិនិយោគសរុប | គម្រោង | 78 | 5.4% | 50.0% | 27.3% |
| ទុនវិនិយោគ | លានដុល្លារអាមេរិក | 1,199.16 | 57.7% | 231.7% | 19.0% |
| **ទេសចរណ៍** | | | | | |
| ភ្ញៀវទេសចរអន្តរជាតិ | នាក់ | 1,346,950 | 4.5% | 77.5% | 210.2% |
| ភ្ញៀវទេសចរផ្ទៃក្នុង | នាក់ | 2,542,962 | -58.8% | -3.9% | 34.4% |

| បរិយាយ | ឯកតា | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|---|
| | | ត្រីមាសទី៣ | ត្រីមាសមុន | ត្រីមាសទី៣ឆ្នាំមុន | ៩ខែដើមឆ្នាំមុន |
| **សំណង់ទូទាំងប្រទេស** | | | | | |
| គម្រោង | គម្រោង | 749 | -9.3% | -36.3% | -18.2% |
| តម្លៃ | លានដុល្លារអាមេរិក | 2,200.21 | 49.2% | 192.3% | 153.2% |
| **ថ្លៃទំនិញលើទីផ្សារអន្តរជាតិ (ជាមធ្យម)** | | | | | |
| អង្ករ (បាក់៥%) | ដុល្លារអាមេរិក/ តោន | 600.67 | 18.2% | 39.9% | 23.3% |
| ប្រេងឆៅ** | ដុល្លារអាមេរិក/ ធុង | 85.31 | 11.3% | -11.5% | -20.5% |
| កៅស៊ូ (TSR20) | ដុល្លារអាមេរិក/ តោន | 1,336.60 | -0.4% | -7.6% | -16.5% |
| មាស | ដុល្លារអាមេរិក/ អោន | 2,115.90 | -2.5% | 11.7% | 5.9% |

ប្រភព÷ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, វិទ្យាស្ថានជាតិស្ថិតិ និងធនាគារជាតិនៃកម្ពុជា

សម្គាល់÷ *ឥណទានផ្តល់ដោយធនាគារពាណិជ្ជ និងមីក្រូហិរញ្ញវត្ថុ, ** ថ្លៃជាមធ្យមរួមប្រេងឆៅ÷ Brent, WTI និង Dubai

# ២. សូចនាករតាមវិស័យ

## ២.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

*តារាង ២÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (មធ្យមប្រចាំត្រីមាស)*

| បរិយាយ | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|
| | ត្រីមាសទី៣ | ត្រីមាសមុន | ត្រីមាសទី៣ឆ្នាំមុន | ៩ខែដើមឆ្នាំមុន |
| **មុខទំនិញគ្រប់មុខ** | **204.19** | **1.4%** | **3.0%** | **1.8%** |
| អាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង | 254.23 | 1.4% | 3.9% | 3.0% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | 184.78 | 1.3% | 3.2% | 2.0% |
| សម្លៀកបំពាក់ និងស្បែកជើង | 182.65 | 1.6% | 3.8% | 2.9% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | 142.01 | 0.9% | 1.6% | -0.2% |
| គ្រឿងសង្ហារិម សម្ភារប្រើប្រាស់ និងការថែទាំ | 163.56 | 0.5% | 1.6% | 1.4% |
| សុខាភិបាល | 143.97 | 0.6% | 1.4% | 0.4% |
| ការដឹកជញ្ជូន | 128.24 | 1.5% | -0.2% | -3.1% |
| គមនាគមន៍ | 66.70 | 0.3% | 0.3% | 0.0% |
| ការកំសាន្ត និងវប្បធម៌ | 133.24 | 1.3% | 3.6% | 2.9% |
| ការសិក្សា | 172.29 | 0.7% | 2.0% | 1.6% |
| ភោជនីយដ្ឋាន | 331.10 | 2.0% | 2.7% | 1.6% |
| ទំនិញ និងសេវាកម្មផ្សេងៗ | 171.40 | 0.7% | 2.9% | 1.9% |

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ (ឆ្នាំគោល ២០០៦)

*រូបភាព ១÷ ស្ថានភាពអតិផរណា (មធ្យមប្រចាំត្រីមាស)*




ប្រភព: វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ

## ២.២. អត្រាប្តូរប្រាក់

*តារាង ៣÷ អត្រាប្តូរប្រាក់រៀលធៀបដុល្លារអាម៉េរិក (មធ្យមប្រចាំត្រីមាស)*

| អត្រាប្តូរប្រាក់មធ្យមប្រចាំខែ | ត្រីមាសទី១ | ត្រីមាសទី៣ | ត្រីមាសទី៣ | ត្រីមាសទី៤ |
|---|---|---|---|---|
| 2015 | 4,042.67 | 4,055.67 | 4,092.00 | 4,050.67 |
| 2016 | 4,022.67 | 4,054.67 | 4,094.38 | 4,041.72 |
| 2017 | 4,016.14 | 4,047.37 | 4,079.54 | 4,037.16 |
| 2018 | 4,011.98 | 4,046.47 | 4,073.46 | 4,047.26 |
| 2019 | 4,006.33 | 4,052.39 | 4,086.61 | 4,063.09 |
| 2020 | 4,064.19 | 4,087.18 | 4,094.59 | 4,063.78 |
| 2021 | 4,059.22 | 4,063.14 | 4,076.17 | 4,072.04 |
| 2022 | 4,063.26 | 4,056.07 | 4,101.37 | 4,128.65 |
| **2023** | **4,084.16** | **4,103.60** | **4,132.61** | |

*ប្រភព: ធនាគារជាតិនៃកម្ពុជា*

*រូបភាព ២÷ ស្ថានភាពអតិផរណា និងអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស)*




ប្រភព: ធនាគារជាតិនៃកម្ពុជា

## ២.៣. ស្ថានភាពហិរញ្ញវត្ថុសាធារណៈ

*តារាង ៤÷ តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (TOFE) (គិតជាប៊ីលានរៀល)*

| បរិយាយ | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|
| | ត្រីមាសទី៣ | ត្រីមាសមុន | ត្រីមាសទី៣ឆ្នាំមុន | ៩ខែដើមឆ្នាំមុន |
| **I. ចំណូលក្នុងប្រទេស** | **5,414.42** | **-15.7%** | **-6.6%** | **-0.8%** |
| ១. ចំណូលចរន្ត | 5,405.13 | -15.6% | -6.6% | -0.8% |
| ក. ចំណូលសារពើពន្ធ | 4,802.18 | -15.5% | -7.7% | -2.9% |
| ខ. ចំណូលមិនមែនសារពើពន្ធ | 602.95 | -16.3% | 3.1% | 23.7% |
| ២. ចំណូលមូលធន | 9.29 | -44.7% | -33.6% | -7.8% |
| **II. ចំណាយសរុប** | **7,154.68** | **-3.1%** | **13.7%** | **11.4%** |
| ១. ចំណាយចរន្ត | 4,661.76 | 2.2% | 11.6% | 13.2% |
| ក. ការពារ និងសន្តិសុខជាតិ | 1,110.01 | -3.8% | 9.0% | 10.4% |
| ខ. រដ្ឋបាលស៊ីវិល | 3,311.17 | -1.7% | 12.1% | 14.4% |

| បរិយាយ | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|
| | ត្រីមាសទី៣ | ត្រីមាសមុន | ត្រីមាសទី៣ឆ្នាំមុន | ៩ខែដើមឆ្នាំមុន |
| គ. ចំណាយការប្រាក់ | 240.57 | 479.1% | 16.2% | 8.9% |
| ២. ចំណាយមូលធន | 2,492.92 | -11.5% | 17.9% | 8.2% |
| ឱនភាពចរន្ត (សាច់ប្រាក់) | 743.37 | -59.7% | -53.7% | -28.0% |
| ឱនភាពទូទៅ (សាច់ប្រាក់) | (1,740.27) | 81.7% | 252.6% | 412.9% |
| **III. ហិរញ្ញប្បទាន** | **1,740.27** | **81.7%** | **252.6%** | **412.9%** |
| ១. ហិរញ្ញប្បទានក្រៅស្រុក | 629.70 | -76.8% | -29.6% | -3.2% |
| ២. ហិរញ្ញប្បទានក្នុងស្រុក | 35.45 | 107.9% | -71.0% | -296.6% |
| ៣. ប្រតិបត្តិការកំពុងដំណើរការ | 1,075.11 | -160.5% | -305.3% | -62.7% |

ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព ៣៖ស្ថានភាពហិរញ្ញវត្ថុសាធារណៈ (គិតជាប៊ីលានរៀល)*




ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.៤. ស្ថានភាពរូបិយវត្ថុ និងឥណទាន

*តារាង ៥÷ ស្ថានភាពរូបិយវត្ថុ (គិតជាប៊ីលានរៀល)*

| បរិយាយ | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|
| | ត្រីមាសទី៣ | ត្រីមាសមុន | ត្រីមាសទី៣ឆ្នាំមុន | ៩ខែដើមឆ្នាំមុន |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **50,548.37** | **8.0%** | **29.9%** | **1.9%** |
| ឥណទេយ្យពីអនិវាសជន | 100,414.41 | 1.3% | 8.9% | 2.1% |
| ទ្រព្យអកម្មចំពោះអនិវាសជន | (49,866.04) | -4.7% | -6.4% | 2.3% |
| **ឥណទេយ្យក្នុងស្រុក** | **212,828.17** | **1.9%** | **7.7%** | **11.3%** |
| ឥណទេយ្យសុទ្ធចំពោះរដ្ឋាភិបាល | (21,034.32) | -6.2% | -2.2% | 1.7% |
| ឥណទេយ្យចំពោះរដ្ឋាភិបាល | 319.16 | 16.1% | 76.1% | 130.4% |
| ទ្រព្យអកម្មរដ្ឋាភិបាល | (21,353.48) | -5.9% | -1.5% | 2.4% |
| ឥណទេយ្យសុទ្ធចំពោះវិស័យផ្សេងៗ | 233,862.49 | 1.1% | 6.7% | 10.3% |
| ឥណទេយ្យចំពោះរដ្ឋាភិបាលថ្នាក់ក្រោមជាតិ | - | - | - | - |
| ឥណទេយ្យចំពោះគ្រឹះស្ថានសាធារណៈមិនមែនហិរញ្ញវត្ថុ | 4.78 | 37.3% | -90.9% | -89.6% |
| ឥណទេយ្យចំពោះវិស័យឯជន | 233,857.71 | 1.1% | 6.7% | 10.3% |
| **ទ្រព្យអកម្មជារូបិយវត្ថុទូទៅ (M2)** | **187,237.55** | **2.6%** | **10.5%** | **9.2%** |
| *ក្នុងនោះជារូបិយបណ្ណបរទេស* | 155,758.75 | 2.8% | 10.1% | 8.6% |
| រូបិយវត្ថុ (M1) | 42,281.74 | -1.3% | -1.0% | -2.9% |
| រូបិយវត្ថុក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើ | 14,516.76 | -3.0% | 3.7% | 3.7% |
| ប្រាក់បញ្ញើចរន្ត | 27,764.98 | -0.3% | -3.3% | -6.1% |
| ប្រាក់បញ្ញើផ្សេងទៀត | 144,955.81 | 3.8% | 14.4% | 13.5% |
| មូលបត្រមិនមែនភាគហ៊ុន | - | - | - | - |
| **ទុនបម្រុងជារូបិយបណ្ណបរទេសដុល (លានដុល្លារអាមេរិក)** | **18,070.63** | **-1.7%** | **2.3%** | **-5.1%** |

*ប្រភព: ធនាគារជាតិនៃកម្ពុជា*

*រូបភាព ៤÷ស្ថានភាពរូបិយវត្ថុប្រចាំត្រីមាស*




ប្រភព: ធនាគារជាតិនៃកម្ពុជា

*តារាង ៦÷ ស្ថានភាពឥណទានផ្តល់ដោយធនាគារពាណិជ្ជ (គិតជាប៊ីលានរៀល)*

| បរិយាយ | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|
| | ត្រីមាសទី៣ | ត្រីមាសមុន | ត្រីមាសទី៣ឆ្នាំមុន | ៩ខែដើមឆ្នាំមុន |
| គ្រឹះស្ថានហិរញ្ញវត្ថុ | 8,050.67 | 0.1% | -2.3% | 2.4% |
| ធនាគារជាតិនៃកម្ពុជា | - | - | - | - |
| គ្រឹះស្ថានហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | 6,171.12 | 4.0% | 1.5% | 3.5% |
| គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត | 1,879.55 | -10.9% | -12.9% | -0.8% |
| គ្រឹះស្ថានមិនបម្រើសេវាហិរញ្ញវត្ថុ | 158,384.58 | 10.6% | 16.8% | 13.9% |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 19,166.01 | 22.2% | 27.1% | 18.6% |
| ឧស្សាហកម្មរ៉ែ | 1,055.03 | -1.7% | 3.1% | 14.7% |
| កម្មន្តសាល | 9,156.09 | 5.5% | 19.1% | 20.6% |
| ការផ្គត់ផ្គង់សេវាសាធារណៈ | 2,454.76 | 8.9% | 27.9% | 18.9% |
| សំណង់ | 20,366.70 | 11.2% | 16.1% | 11.8% |
| ការជួញដូរដុំ | 18,680.10 | 1.7% | 3.7% | 7.7% |
| ការជួញដូររាយ | 37,103.23 | 16.4% | 23.4% | 17.3% |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 8,481.64 | 4.1% | 2.9% | 5.5% |

| បរិយាយ | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|
| | ត្រីមាសទី៣ | ត្រីមាសមុន | ត្រីមាសទី៣ឆ្នាំមុន | ៩ខែដើមឆ្នាំមុន |
| ដឹកជញ្ជូន និងស្តុកបណ្តោះអាសន្ន | 6,084.06 | 19.2% | 23.5% | 14.0% |
| បណ្តាញព័ត៌មាន និងទូរគមនាគមន៍ | 1,121.98 | 6.9% | 5.8% | 0.8% |
| អាជីវកម្មជួល និងភតិសន្យាប្រតិបត្តិការ | 2,764.34 | 18.8% | -0.6% | -5.3% |
| ការជួញដូរអចលនទ្រព្យ | 21,248.38 | 8.3% | 23.4% | 18.8% |
| សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងៗ | 10,702.28 | 0.2% | 5.9% | 10.4% |
| តម្រូវការផ្ទាល់ខ្លួន | 49,641.27 | 11.6% | 16.8% | 12.3% |
| ការឱ្យខ្ចីជាបុគ្គល | 20,192.91 | 32.1% | 29.4% | 8.4% |
| ការឱ្យខ្ចីតាមបណ្ណឥណទាន | 640.52 | 10.8% | 36.3% | 40.0% |
| ការឱ្យខ្ចីទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន | 28,807.85 | 0.6% | 9.0% | 14.3% |
| ឥណទានផ្សេងៗ | 3,961.40 | 39.8% | 62.6% | 41.2% |
| **សរុប** | **220,037.93** | **10.8%** | **16.5%** | **13.4%** |
| *ក្នុងនោះជារៀល* | *24,181.69* | *13.1%* | *17.9%* | *12.0%* |

*ប្រភព: ធនាគារជាតិនៃកម្ពុជា*

*រូបភាព ៥÷ស្ថានភាពឥណទានផ្តល់ដោយធនាគារពាណិជ្ជប្រចាំត្រីមាស*




ប្រភព: ធនាគារជាតិនៃកម្ពុជា

*តារាង ៧÷ ស្ថានភាពឥណទានផ្តល់ដោយមីក្រូហិរញ្ញវត្ថុ (គិតជាប៊ីលានរៀល)*

| បរិយាយ | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|
| | ត្រីមាសទី៣ | ត្រីមាសមុន | ត្រីមាសទី៣ឆ្នាំមុន | ៩ខែដើមឆ្នាំមុន |
| ស្ថាប័នហិរញ្ញវត្ថុ | 15.92 | -47.6% | -66.0% | -34.6% |
| កសិកម្ម | 3,721.95 | -47.1% | -43.8% | -6.3% |
| កម្មន្តសាល | 412.29 | -46.0% | -38.9% | 3.4% |
| ពាណិជ្ជកម្ម | 4,889.03 | -47.4% | -44.2% | -6.0% |
| គ្រួសារ | 7,275.87 | -47.0% | -41.2% | -2.2% |
| សេវាកម្ម | 2,834.93 | -47.3% | -45.3% | -9.4% |
| ដឹកជញ្ជូន | 876.34 | -47.6% | -48.8% | -15.6% |
| សំណង់ | 876.44 | -50.1% | -49.2% | -9.6% |
| ឥណទានផ្សេងៗ | 336.99 | -37.6% | -46.0% | -5.1% |
| **សរុប** | **21,239.77** | **-47.2%** | **-43.7%** | **-5.8%** |

ប្រភព: ធនាគារជាតិនៃកម្ពុជា

*រូបភាព ៦÷ចំណែក នៃឥណទានតាមវិស័យផ្តល់ដោយមីក្រូហិរញ្ញវត្ថុប្រចាំត្រីមាស*







ប្រភព: ធនាគារជាតិនៃកម្ពុជា

## ២.៥. ស្ថានភាពពាណិជ្ជកម្ម

*តារាង ៨÷ ការនាំចូលតាមមុខទំនិញសំខាន់ៗ (គិតជាលានដុល្លារអាម៉េរិក)*

| មុខទំនិញ | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|
| | ត្រីមាសទី៣ | ត្រីមាសមុន | ត្រីមាសទី៣ឆ្នាំមុន | ៩ខែដើមឆ្នាំមុន |
| ថ្នាំពេទ្យ | 76.02 | -23.9% | -4.4% | 91.1% |
| ភេសជ្ជៈ គ្រឿងស្រវឹង និងបារី | 133.09 | 4.1% | 0.1% | 95.2% |
| ស្ករស និងប៊ីចេង | 23.37 | -11.0% | 34.2% | 122.7% |
| ប្រេងឆា និងអាហារផ្សេងៗ | 184.78 | 10.0% | 20.2% | 111.2% |
| គ្រឿងសំណង់ | 494.55 | -1.8% | 17.3% | 100.8% |
| គ្រឿងអេឡិចត្រូនិក | 252.35 | -8.4% | 1.2% | 115.5% |
| វាយនភណ្ឌនិងសម្លៀកបំពាក់ | 1,291.70 | -6.6% | -1.0% | 87.9% |
| យានយន្ត | 236.96 | -2.8% | -50.9% | 65.6% |
| គ្រឿងបន្លាស់ថយន្ត | 8.13 | 15.2% | 29.5% | 206.4% |
| បរិក្ខារត្រជាក់ | 17.87 | -28.6% | 4.1% | 124.2% |
| ប្រេងឥន្ធនៈ | 631.89 | 6.1% | -17.7% | 87.2% |
| មាស | 55.15 | - | -96.4% | 1.3% |
| ជីកសិកម្ម | 88.98 | -6.8% | 47.5% | 118.2% |
| ផ្សេងៗ | 2,547.76 | -9.6% | -4.1% | 98.2% |
| **សរុប** | **6,042.61** | **-5.1%** | **-23.5%** | **76.9%** |

ប្រភព: អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព ៧÷ ទំហំនាំចូលគ្រឿងសំណង់, ប្រេងឥន្ធនៈ, យានយន្ត, វាយនភណ្ឌនិងសម្លៀកបំពាក់ (លានដុល្លារអាមេរិក)*




ប្រភព: អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព ៨÷ ស្ថានភាពនាំចូលពីទីផ្សារអន្តរជាតិ (គិតជាលានដុល្លារអាមេរិក)*




ប្រភព: អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*តារាង ៩÷ មុខទំនិញនាំចេញ (គិតជាលានដុល្លារអាមេរិក)*

| មុខទំនិញ | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|
| | ត្រីមាសទី៣ | ត្រីមាសមុន | ត្រីមាសទី៣ឆ្នាំមុន | ៩ខែដើមឆ្នាំមុន |
| សម្លៀកបំពាក់ | 2,275.10 | 13.8% | -14.6% | -17.4% |
| ស្បែកជើង | 291.16 | -22.7% | -39.1% | -25.1% |
| កាបូប | 422.70 | -2.7% | -3.2% | -13.2% |
| វាយនភណ្ឌផ្សេងៗ | 76.42 | 42.9% | 22.8% | -7.3% |
| គ្រឿងអេឡិចត្រូនិក និងភាគបំណែក | 56.27 | 8.4% | 37.3% | 0.5% |
| គ្រឿងបន្លាស់រថយន្ត | 61.84 | 6.7% | 61.0% | 40.9% |
| កង់ | 81.34 | -40.5% | -66.6% | -48.6% |
| ឈើមូល | 0.41 | -52.2% | -67.3% | -51.0% |
| ឈើកែច្នៃ (Veneer) | 0.00 | - | -100.0% | -71.5% |
| ក្តារបន្ទះ | 56.81 | 17.5% | 27.5% | -14.5% |
| ឈើកែច្នៃផ្សេងទៀត | 95.51 | 24.3% | 44.3% | 8.2% |
| អង្ករ | 98.97 | -4.1% | 13.2% | 12.6% |
| ដំឡូងមី | 134.69 | 112.1% | 89.7% | 0.8% |
| ពោតក្រហម | 11.37 | 170.7% | -61.2% | -44.3% |
| សណ្តែក | 0.23 | -18.8% | - | -17.3% |
| ចេក | 26.67 | -43.7% | -27.8% | -26.6% |
| ស្វាយ | 7.19 | -81.4% | -20.7% | -8.9% |
| ស្វាយចន្ទី | 28.49 | -82.3% | 86.3% | 49.6% |
| កៅស៊ូ | 123.18 | 74.7% | 35.2% | 5.1% |
| ស្ករស | 18.48 | -59.6% | 187.1% | 49.6% |
| ផលិតផលជលផល | 0.13 | 15.1% | 26.2% | 27.7% |
| កសិផលផ្សេងទៀត | 248.16 | 46.6% | 69.5% | 47.7% |
| បារី | 1.66 | -16.0% | -28.7% | 12.3% |
| ខ្សែភ្លើង និងបង្គុំខ្សែភ្លើង | 53.56 | -27.9% | -39.1% | -21.7% |
| សំបកកំប៉ុង និងគម្របកំប៉ុង | 0.22 | 258.9% | 8.2% | 21.9% |
| មាស | 110.34 | -75.8% | 135.1% | 259.7% |
| ផ្សេងៗ | 1,851.62 | 15.8% | 58.0% | 52.3% |
| **សរុប** | **6,132.53** | **1.0%** | **4.3%** | **2.0%** |

ប្រភព: អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព ៩÷ ស្ថានភាពមុខទំនិញនាំចេញសំខាន់ៗ (គិតជាលានដុល្លារអាមេរិក)*




ប្រភព: អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព ១០÷ ស្ថានភាពនាំចេញទៅទីផ្សារអន្តរជាតិ (គិតជាលានដុល្លារអាមេរិក)*




ប្រភព: អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.៦. ស្ថានភាពវិនិយោគឯកជន

*តារាង ១០÷ ស្ថិតិវិនិយោគវិស័យឯកជន (អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)*

| ការអនុញ្ញាតវិនិយោគ | ឯកតា | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|---|
| | | ត្រីមាសទី៣ | ត្រីមាសមុន | ត្រីមាសទី៣ឆ្នាំមុន | ៩ខែដើមឆ្នាំមុន |
| **គម្រោងវិនិយោគសរុប** | **គម្រោង** | **78** | **5.4%** | **50.0%** | **27.3%** |
| **បង្កើតការងារសរុប** | **កន្លែង** | **104,224** | **33.4%** | **158.8%** | **107.7%** |
| **ទុនវិនិយោគសរុប** | **លានដុល្លារអាមេរិក** | **1,199.2** | **57.7%** | **231.7%** | **19.0%** |
| ការវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស | | | | | |
| គម្រោងវិនិយោគ | គម្រោង | 23 | 21.1% | 21.1% | 47.1% |
| បង្កើតការងារ | កន្លែង | 24,548 | 39.2% | 201.9% | 208.3% |
| ទុនវិនិយោគលើវិស័យ | លានដុល្លារអាមេរិក | 334.3 | 28.8% | 71.9% | 15.3% |
| កសិកម្ម | លានដុល្លារអាមេរិក | - | - | - | - |
| ថាមពល | លានដុល្លារអាមេរិក | - | - | - | - |
| ឧស្សាហកម្ម | លានដុល្លារអាមេរិក | 334.3 | 28.8% | 71.9% | 15.3% |
| សេវាកម្ម | លានដុល្លារអាមេរិក | - | - | - | - |
| ទេសចរណ៍ | លានដុល្លារអាមេរិក | - | - | - | - |
| ការវិនិយោគក្រៅតំបន់សេដ្ឋកិច្ចពិសេស | | | | | |
| គម្រោងវិនិយោគ | គម្រោង | 55 | 0.0% | 66.7% | 21.6% |
| បង្កើតការងារ | កន្លែង | 79,676 | 31.7% | 147.9% | 92.1% |
| ទុនវិនិយោគលើវិស័យ | លានដុល្លារអាមេរិក | 864.8 | 72.7% | 417.7% | 20.5% |
| កសិកម្ម | លានដុល្លារអាមេរិក | 13.7 | -91.0% | - | 155.9% |
| ថាមពល | លានដុល្លារអាមេរិក | - | - | - | -100.0% |
| ឧស្សាហកម្ម | លានដុល្លារអាមេរិក | 759.9 | 117.8% | 354.9% | 53.3% |
| សេវាកម្ម | លានដុល្លារអាមេរិក | - | - | - | - |
| ទេសចរណ៍ | លានដុល្លារអាមេរិក | 91.2 | - | - | - |

ប្រភព: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC), សម្គាល់ការអនុញ្ញាតវិនិយោគសរុប ដោយរួមបញ្ចូលការពង្រីកគម្រោងក្រៅតំបន់សេដ្ឋកិច្ចពិសេស

*រូបភាព ១១÷ស្ថានភាពវិនិយោគឯកជន*




ប្រភពៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)

## ២.៧. ស្ថានភាពទេសចរណ៍

*តារាង ១១÷ ចំនួនភ្ញៀវទេសចរអន្តរជាតិ*

| បរិយាយ | ឯកតា | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|---|
| | | ត្រីមាសទី៣ | ត្រីមាសមុន | ត្រីមាសទី៣ឆ្នាំមុន | ៩ខែដើមឆ្នាំមុន |
| តាមផ្លូវអាកាស | នាក់ | 427,867 | -0.8% | 87.5% | 185.9% |
| ភ្នំពេញ | នាក់ | 323,768 | -3.6% | 80.4% | 158.8% |
| សៀមរាប | នាក់ | 100,225 | 9.5% | 134.5% | 370.9% |
| កងកេង | នាក់ | 3,874 | -0.2% | -36.2% | -7.1% |
| តាមផ្លូវគោក និងផ្លូវទឹក | នាក់ | 919,083 | 7.2% | 73.2% | 224.5% |
| ផ្លូវគោក | នាក់ | 909,683 | 7.9% | 72.6% | 222.7% |
| ផ្លូវទឹក | នាក់ | 9,400 | -33.4% | 154.5% | 394.3% |
| **សរុប** | **នាក់** | **1,346,950** | **4.5%** | **77.5%** | **210.2%** |

ប្រភពៈ ក្រសួងទេសចរណ៍

*រូបភាព ១២÷ កំណើនភ្ញៀវទេសចរអន្តរជាតិ (គិតជា %)*




ប្រភព៖ ក្រសួងទេសចរណ៍

*រូបភាព ១៣÷ កំណើនភ្ញៀវទេសចរអន្តរជាតិពីតំបន់នីមួយៗ (គិតជា %)*




ប្រភព៖ ក្រសួងទេសចរណ៍

## ២.៨. ស្ថានភាពសំណង់

*តារាង ១២÷ សំណង់ទូទាំងប្រទេស*

| បរិយាយ | ឯកតា | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|---|
| | | ត្រីមាសទី៣ | ត្រីមាសមុន | ត្រីមាសទី៣ឆ្នាំមុន | ៩ខែដើមឆ្នាំមុន |
| សំណង់សាធារណៈ | គម្រោង | 10 | -52.4% | -28.6% | 12.2% |
| សំណង់លំនៅឋាន និងភូមិគ្រឹះ | គម្រោង | 591 | -12.7% | -41.7% | -23.4% |
| សំណង់ឧស្សាហកម្ម | គម្រោង | 66 | 13.8% | -8.3% | 27.1% |
| សំណង់ពាណិជ្ជកម្ម | គម្រោង | 60 | 20.0% | -11.8% | 10.3% |
| សំណង់ទេសចរណ៍ | គម្រោង | 19 | -5.0% | 216.7% | 108.3% |
| សំណង់វិនិយោគផ្សេងៗ | គម្រោង | 3 | - | 200.0% | 200.0% |
| **សរុប** | **គម្រោង** | **749** | **-9.3%** | **-36.3%** | **-18.2%** |
| **ក្រឡាផ្ទៃសាងសង់** | **ម៉ែត្រការ៉េ** | **5,173,727** | **37.2%** | **157.8%** | **146.4%** |
| **តម្លៃ** | **លានដុល្លារអាម៉េរិក** | **2,200.21** | **49.2%** | **192.3%** | **153.2%** |

ប្រភព: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

*រូបភាព ១៤÷ ចំណែកនៃផ្ទៃក្រឡាសាងសង់តាមប្រភេទ (គិតជា %)*




ប្រភព: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ៣. ថ្លៃទំនិញសំខាន់ៗ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ

*តារាង ១៣៖ ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ជាមធ្យម)*

| មុខទំនិញ | ឯកតា | ទីផ្សារ | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|---|---|
| | | | ត្រីមាសទី៣ | ត្រីមាសមុន | ត្រីមាសទី៣ឆ្នាំមុន | ៩ខែដើមឆ្នាំមុន |
| អង្ករ (បាក់៥%) | ដុល្លារអាម៉េរិក/តោន | បាងកក | 600.67 | 18.2% | 39.9% | 23.3% |
| ប្រេងឆៅ | ដុល្លារអាម៉េរិក/ធុង | ក្រុងឡុងដ៍ | 85.31 | 11.3% | -11.5% | -20.5% |
| កៅស៊ូ | ដុល្លារអាម៉េរិក/តោន | សិង្ហបុរី | 1,336.60 | -0.4% | -7.6% | -16.5% |
| មាស | ដុល្លារអាម៉េរិក/អោន | ក្រុងឡុងដ៍ | 2,115.90 | -2.5% | 11.7% | 5.9% |
| ពោតក្រហម | ដុល្លារអាម៉េរិក/តោន | ស៊ីកាហ្គោ | 224.60 | -18.4% | -27.2% | -16.6% |
| សណ្តែកសៀង | ដុល្លារអាម៉េរិក/តោន | ស៊ីកាហ្គោ | 612.27 | 1.9% | -8.8% | -10.3% |
| ប្រេងដូង | ដុល្លារអាម៉េរិក/តោន | រ៉ុតធើដាំ | 1,072.71 | 2.7% | -22.9% | -40.5% |
| ស្ករស | ដុល្លារអាម៉េរិក/តោន | ក្រុងឡុងដ៍ | 355.47 | -0.1% | 8.0% | 1.7% |

ប្រភព: គេហទំព័រធនាគារពិភពលោក (www.worldbank.org)

*រូបភាព ១៥ ៖ ទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ជាមធ្យម)*




ប្រភព: គេហទំព័រធនាគារពិភពលោក (www.worldbank.org)

*តារាង ១៤÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ជាមធ្យមប្រចាំត្រីមាស, ឆ្នាំគោល ២០១០=១០០)*

| មុខទំនិញ | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|
| | ត្រីមាសទី៣ | ត្រីមាសមុន | ត្រីមាសទី៣ឆ្នាំមុន | ៩ខែដើមឆ្នាំមុន |
| **មិនមែនថាមពល** | **110.19** | **-2.0%** | **-5.1%** | **-12.3%** |
| ផលិតផលកសិកម្ម | 112.37 | -2.2% | -5.0% | -8.5% |
| ម្ហូបអាហារ | 128.50 | -3.3% | -6.3% | -17.2% |
| ឈើ | 79.75 | -0.2% | 4.9% | -4.0% |
| លោហៈធាតុ | 100.80 | -2.2% | 0.2% | 3.0% |
| ជីគីមី | 153.58 | 3.1% | -28.6% | -43.3% |

ប្រភព: គេហទំព័រធនាគារពិភពលោក (www.worldbank.org)

*រូបភាព ១៦ ÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ជាមធ្យមប្រចាំត្រីមាស, ឆ្នាំគោល ២០១០=១០០)*




*ចំណាំ÷អាហារ (ធញ្ញជាតិ, ប្រេងឆា និងអាហារផ្សេងៗ), ភេសជ្ជៈ (កាកាវ, កាហ្វេ និងតែ), វត្ថុធាតុដើម (ឈើមូល, កប្បាស, កៅស៊ូ និងថ្នាំជក់)*

ប្រភព: គេហទំព័រធនាគារពិភពលោក (www.worldbank.org)

*តារាង ១៥÷ អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិធៀបនឹងដុល្លារអាមេរិក (ជាមធ្យមប្រចាំត្រីមាស)*

| រូបិយបណ្ណ | ២០២៣ | ការប្រែប្រួល | | |
|---|---|---|---|---|
| | ត្រីមាសទី៣ | ត្រីមាសមុន | ត្រីមាសទី៣ឆ្នាំមុន | ៩ខែដើមឆ្នាំមុន |
| ជប៉ុន (Yen) | 145.51 | 3.7% | 4.4% | 7.8% |
| ហុងកុង (Dollar) | 7.82 | -0.2% | -0.3% | 0.0% |
| សិង្ហបុរី (Dollar) | 1.35 | 0.1% | -4.0% | -2.8% |
| ម៉ាឡេស៊ី (Ringgit) | 4.63 | 32.5% | 2.3% | -4.6% |
| ហ្វីលីពីន (Peso) | 56.07 | 45.8% | -1.4% | -7.6% |
| ថៃ (Baht) | 35.23 | 1.2% | -4.7% | -0.6% |
| ឥណ្ឌូនេស៊ី (Rupiah) | 15,260.07 | 2.5% | 1.8% | 2.8% |
| កូរ៉េខាងត្បូង (Won) | 1,313.92 | -0.8% | -3.4% | 2.3% |
| តៃវ៉ាន់ (Dollar) | 31.77 | 3.2% | 3.5% | 5.4% |
| ចិន (Yuan Renminbi) | 7.24 | 2.2% | 4.3% | 6.3% |
| ឡាវ (Kip) | 19,516.50 | 9.4% | 26.7% | 35.2% |
| វៀតណាម (Dong) | 24,041.53 | 2.3% | 2.2% | 2.4% |
| ឥណ្ឌា (Rupee) | 82.69 | 0.7% | 3.0% | 6.0% |
| រុស្ស៊ី (Ruble) | 94.97 | 15.7% | 58.7% | 21.0% |
| អូស្ត្រាលី (Dollar) | 1.53 | 0.9% | 3.9% | 5.7% |
| អង់គ្លេស (Pound) | 0.79 | -0.4% | -8.0% | -0.4% |
| អឺរ៉ុប (Euro) | 0.92 | -0.1% | -7.9% | -3.7% |

ប្រភព: គេហទំព័រអូអែនដា (www.oanda.com)